ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

លេខ...០៦៩ ប្រក...

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៦.....

# ប្រកាស

## ស្តីពីឯកសណ្ឋានមគ្គុទ្ទេសក៍ទេសចរណ៍ នៃព្រះរាជាណាចក្រកម្ពុជា

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញប្រកាសលេខ ២៨ ប្រក ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០០១ ស្តីពីការផ្តល់អាជ្ញាប័ណ្ណជូនមគ្គុទ្ទេសក៍ទេសចរណ៍
- យោងប្រកាសលេខ ៤៤ ប្រក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៧ ស្តីពីការកំណត់ឯកសណ្ឋានមគ្គុទ្ទេសក៍ទេសចរណ៍
- យោងប្រកាសលេខ ៨០ ប្រក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការកែប្រែប្រការ១ នៃប្រកាសស្តីពីការកំណត់ឯកសណ្ឋានមគ្គុទ្ទេសក៍ទេសចរណ៍
- យោងប្រកាសលេខ ០៣៦ ប្រក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីឯកសណ្ឋានមគ្គុទ្ទេសក៍ទេសចរណ៍
- យោងតាមសំណើរបស់សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ លិខិតចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៦

## សម្រេច

**ប្រការ ១ :** ឯកសណ្ឋានមគ្គុទ្ទេសក៍ទេសចរណ៍ត្រូវកំណត់ដូចខាងក្រោម៖

# ៣ មហាវិថីព្រះមុនីវង្ស ភ្នំពេញ ១២២៥៨ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥) ២៣ ២១៣ ៧៤១ ទូរសារ: (៨៥៥) ២៣ ២២០ ៧០៤, អ៊ីមែល: info@mot.gov.kh Website: www.mot.gov.kh

ក-បុរស ៖

- អាវសឺមីដៃវែងពណ៌ពងមាន់ កខុប ហោប៉ៅពីរមានគំរប
- ខោជើងវែងបែបសកល ពណ៌ខៀវទឹកប៊ិចចាស់
- ក្រវ៉ាត់កធ្វើអំពីផាមូង ពណ៌ស្វាយកំភេន
- ស្បែកជើងឃ្មុបស្បែក បាតកៅស៊ូ ពណ៌ខ្មៅ និងស្រោមជើងពណ៌ខ្មៅ ( ស្បែកជើងត្រូវចងខ្សែ ក្នុងករណីបំរើភ្ញៀវពិសេស និងពិធីផ្សេងៗ )
- ស្បែកជើងពណ៌ខ្មៅបាតកៅស៊ូ ប្រើប្រាស់ក្នុងពេលជូនដំណើរភ្ញៀវឡើង-ចុះភ្នំ ប្រាសាទ ឬធ្វើដំណើរតាមផ្លូវទឹក

ខ-នារី ៖

- អាវកម្ពុល ពណ៌ពងមាន់ ដៃ ៣ ភាគ ៤
- អាវកម្ពុលក្រណាត់សូត្រ ពណ៌ពងមាន់ ដៃ ៣ ភាគ ៤ ( ក្នុងករណីបំរើភ្ញៀវពិសេស និងពិធីផ្សេងៗ )
- សំពត់ ពណ៌ខៀវទឹកប៊ិចចាស់ ក្រោមក្បាលជង្គង់
- ស្បែកជើងស្បែកពណ៌ខ្មៅ បាតកៅស៊ូមានកែងទាប
- ខោជើងវែងបែបសកល ពណ៌ខៀវទឹកប៊ិចចាស់ ស្បែកជើងពណ៌ខ្មៅបាតកៅស៊ូប្រើប្រាស់ក្នុងពេលជូនដំណើរភ្ញៀវឡើង-ចុះភ្នំ ប្រាសាទ ឬធ្វើដំណើរតាមផ្លូវទឹក

**ប្រការ ២ ៖** ផ្លាកសញ្ញាសំគាល់មគ្គុទ្ទេសក៍ទេសចរណ៍ ៖

- កំណត់យកផ្លាកសញ្ញាក្រសួងទេសចរណ៍ មានសរសេរជាអក្សរខ្មែរ " មគ្គុទ្ទេសក៍ទេសចរណ៍ " នៅខាងលើ និងអក្សរឡាតាំង "TOUR GUIDE" នៅពីខាងក្រោម ដេរភ្ជាប់ពីលើដៃអាវខាងឆ្វេង ដែលមានអង្កត់ផ្ចិតប្រវែង ៧,២សម ។
- ពាក់ផ្លាកឈ្មោះ អត្តលេខសំគាល់ ឈ្មោះខេត្ត-ក្រុង ( ដែលផលិតដោយក្រសួងទេសចរណ៍ ) ពីលើគំរបហោប៉ៅខាងស្តាំ ។
- ពាក់ប័ណ្ណសំគាល់មគ្គុទ្ទេសក៍ទេសចរណ៍នៅក ។

**ប្រការ ៣ ៖** មគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវស្លៀកពាក់ឯកសណ្ឋាន និង សញ្ញាសំគាល់ ដែលបានកំណត់នៅពេលបំពេញការងារនាំភ្ញៀវទេសចរគ្រប់ពេលវេលា ។

**ប្រការ ៤ ៖** ក្នុងពេលបំពេញការងារ មគ្គុទ្ទេសក៍ទេសចរណ៍ណាមិនស្លៀកពាក់ឯកសណ្ឋាន និងសញ្ញាសំគាល់ ដែលបានកំណត់ខាងលើ ត្រូវទទួលពិន័យតាមច្បាប់ជាធរមាន ។

**ប្រការ ៥ ៖** ប្រកាសទាំងឡាយណា ដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។ ឃ

**ប្រការ ៦ :** អគ្គនាយកទេសចរណ៍ អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ ប្រធានគណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍ខេត្ត-ក្រុង នាយកខុទ្ទកាល័យ អធិការ ប្រធានមន្ទីរទេសចរណ៍ខេត្ត-ក្រុង ត្រូវទទួលអនុវត្តតាមខ្លឹមសារប្រកាសនេះ អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**<u>កន្លែងទទួល</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងស្ថាប័នពាក់ព័ន្ធ
- អាជ្ញាធរជាតិទេសចរណ៍កម្ពុជា
- អគ្គស្នងការនគរបាលជាតិ
- សាលាខេត្ត-ក្រុង
- ដូចក្នុងប្រការ ៦ "ដើម្បីអនុវត្ត"
- សមាគមមគ្គុទ្ទេសក៍ទេសចរណ៍
- សមាគមទីភ្នាក់ងារទេសចរណ៍ "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ